# សេចក្តីព្រាងចុងក្រោយលើវិសោធនកម្មសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាន សម្រាប់លក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

**ដោយ ដេវិត សេហ្វើ**

**ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

ក្នុងរយៈពេល២៤ម៉ោងកន្លងទៅនេះ គណៈប្រតិភូចូលរួមសន្និបាតពិនិត្យឡើងវិញលើលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានទទួលសេចក្តីព្រាងចំនួនបីច្បាប់ផ្សេងៗគ្នាដែលស្តីពីឧក្រិដ្ឋកម្មឈ្លានពាន ។ អត្ថបទនេះនឹងធ្វើឲ្យអ្នកអានបានយល់ពីសេចក្តីព្រាងទាំងអស់នេះតាមលំដាប់ ។ អ្នកនឹងអានពីការយល់ឃើញរបស់ខ្ញុំស្តីពីសេចក្តីស្នើសុំទាំងអស់ និងពីការពិនិត្យឡើងវិញដើម្បីឲ្យទទួលបានប្រយោជន៍ផ្សេង ។ សេចក្តីព្រាងដែលសំខាន់ជាងគេបង្អស់នោះគឺសេចក្តីព្រាងទីបី និងសេចក្តីព្រាងចុងក្រោយគេដែលត្រូវបានចែកជូននៅម៉ោង១១យប់ ថ្ងៃទី១០ ខែមិថុនា ។ នេះគឺជាសេចក្តីព្រាងក្រៅផ្លូវការ ដែលសម្រេចដោយលោកប្រធានអង្គសន្និបាតរបស់ប្រទេសជាភាគី គឺលោកអគ្គរដ្ឋទូតវេណាវេសឺ ។ ហើយសេចក្តីព្រាងនេះមានគោលដៅអធិប្បាយអត្ថបទស្តីពីកិច្ចព្រមព្រៀងចុងក្រោយដែលអមជាមួយនឹងជម្រើសមួយចំនួនតូចដែលមានដាក់នៅក្នុងវង់ក្រចកតែប៉ុណ្ណោះ ។ ខ្ញុំនឹងពន្យល់បកស្រាយសេចក្តីព្រាងទីបីសំខាន់ជាងគេបង្អស់ ដែលគណៈប្រតិភូទាំងអស់កំពុងតែពិនិត្យឡើងវិញពេញមួយយប់នោះនៅចុងក្រោយគេ ។ អ្នកអាចរំលងទៅអានផ្នែកទី៣ខាងក្រោមតែម្តង ដើម្បីទទួលបានព័ត៌មានសំខាន់ៗទាក់ទិននឹងការពិភាក្សាវែកញែកចុងក្រោយនាព្រឹកថ្ងៃសុក្រ ម៉ោង១១:៣០នាទីនៅទីក្រុងកាំប៉ាឡា នេះ ។ ប៉ុន្តែ ប្រសិនបើអ្នកចង់ដឹងពីការពិនិត្យឡើងវិញដ៏លម្អិតថា តើសេចក្តីព្រាងបានវិវត្តន៍យ៉ាងដូចម្តេចក្នុងរយៈពេល២៤ម៉ោងមុនរហូតមកដល់ល្ងាចថ្ងៃព្រហស្បតិ៍ លើឯកសារក្រៅផ្លូវការនោះ អ្នកអាចអានផ្នែកទីមួយនិងទីពីរដែលមានសរសេរនៅខាងក្រោម ។ អត្ថបទនេះក៏បានលើកឡើងពីចំណុចដែលខ្ញុំអាក់ខានមិនបានអធិប្បាយនៅក្នុងអត្ថបទមុនរបស់ខ្ញុំកាលពីល្ងាចម្សិលមិញនេះ ។

## ផ្នែកទីមួយ

នៅល្ងាចថ្ងៃពុធ ទី៨ ខែមិថុនា កន្លងទៅនេះ សេចក្តីពិនិត្យឡើងវិញព្រាងលើមាត្រា១៥ស្ទួននៅក្នុងការពិនិត្យឡើងវិញទី២បានចាប់ផ្តើមចែកជូនដល់គណៈប្រតិភូជាផ្លូវការកាលពីព្រឹកថ្ងៃព្រហស្បតិ៍ ទី១០

ខែមិថុនា ។ ការពិនិត្យឡើងវិញនេះគឺជាសេចក្តីស្នើសុំគួរឲ្យចាប់អារម្មណ៍មួយដែលផ្តល់ជាសញ្ញាណល្អ ។ ប៉ុន្តែក្នុងនោះ ក៏មានបញ្ហាមួយចំនួនដែលឯកសារក្រៅផ្លូវការកាលពីថ្ងៃព្រហស្បតិ៍របស់លោកអគ្គរដ្ឋទូត វេណាវេសឺ បានគូសបញ្ជាក់ហើយវាក៏ត្រូវបានពន្យល់បកស្រាយនៅក្នុងផ្នែកទីពីរខាងក្រោមនេះដែរ ។

កិច្ចព្រមព្រៀងនាយប់ថ្ងៃពុធត្រូវបានរៀបចំឡើងដោយប្រទេសកាណាដា និងគណៈប្រតិភូមួយចំនួនផ្សេងទៀតដែលខ្ញុំមិនសូវស្គាល់ ។ ការប្រើប្រាស់ពាក្យថ្មីនៅពេលល្ងាចថ្ងៃពុធនេះនឹងតម្រូវឲ្យវិសោធនកម្មសម្រាប់សន្និបាតពិនិត្យឡើងវិញនេះបែងចែកជាផ្នែកយោងតាមមាត្រា១២១(៥) ដើម្បីធ្វើឲ្យវិសោធនកម្មអាចចូលជាធរមានបានក្នុងរយៈពេលមួយឆ្នាំសម្រាប់ប្រទេសជាភាគីនីមួយៗ ក្រោយពីការផ្តល់សច្ចាប័នលើវិសោធនកម្មរបស់ប្រទេសជាភាគី ត្រូវបានបញ្ជាក់នៅក្នុងវិសោធនកម្មនោះឲ្យបានច្បាស់លាស់ ។ នេះគឺជាបញ្ហាដ៏ពិបាកយោងតាមការបកស្រាយតាមសន្ធិសញ្ញាដ៏តឹងរ៉ឹង ពីព្រោះប្រសិនបើមានវិសោធនកម្មធ្វើឡើងលើមាត្រាផ្សេង ដែលមិនទាក់ទងនឹងយុត្តាធិការតាមសាច់រឿង ដូចជាមាត្រា (៥,៦,៧ ឬ៨) នោះ វិសោធនកម្មនេះត្រូវតែមានលក្ខណៈស្របតាមនីតិវិធីផ្តល់សច្ចាប័នរបស់មាត្រា១២១(៤) ។ វិសោធនកម្មយោងតាមមាត្រា១២១(៤)តម្រូវឲ្យមានការផ្តល់សច្ចាប័នដោយប្រទេសជាភាគីជាសម្លេង ប្រាំពីរ លើ ប្រាំបី មុននឹងវិសោធនកម្មទាំងនេះដាក់ចូលជាធរមាន ។ អ្វីដែលត្រូវបានណែនាំឲ្យធ្វើកាលពីល្ងាចថ្ងៃទី១០ ខែមិថុនានោះគឺ ដាក់បញ្ចូលវិសោធនកម្មទាំងអស់ក្នុងនីតិវិធីរបស់មាត្រា១២១(៥) ដោយសារតែការចែងនៅក្នុងកិច្ចព្រមព្រៀងរបស់សន្និបាតពិនិត្យឡើងវិញណែនាំថា វិសោធនកម្មត្រូវអនុញ្ញាតឲ្យធ្វើឡើងលុះត្រាតែមានសម្លេងគាំទ្រចំនួនពីរភាគបីពីសំណាក់សភាសន្និបាតប្រទេសជាភាគីដែលអនុវត្តតាមមាត្រា១២១(៣) ។ ការធ្វើដូច្នេះហាក់បីដូចជាងាយ ប៉ុន្តែវាក៏មានចោទជាបញ្ហាទាក់ទងនឹងសន្ធិសញ្ញាផ្នែកច្បាប់មួយចំនួនដែរ ។ សំណួរខ្លះក្នុងចំណោមសំណួរទាំងអស់នោះ អាចដោះស្រាយបានតាមរយៈការទទួលស្គាល់វិសោធនកម្មទាំងអស់ឲ្យដាក់ទៅក្នុងមាត្រា៥ ឬក៏មាត្រា៨ ដែលត្រូវស្ថិតនៅក្នុងប្រព័ន្ធគ្រប់គ្រងច្បាប់របស់មាត្រា១២១(៥) ។ នេះគឺជាបញ្ហាដ៏សំខាន់ ពីព្រោះកិច្ចព្រមព្រៀងពិតប្រាកដកំពុងតែត្រូវបានតាក់តែងឡើងដោយយោងតាមផ្នែកជាច្រើនរបស់មាត្រា១៥ទាក់ទិននឹងបញ្ហាលក្ខខណ្ឌ (sic) លក្ខន្តិកៈយុត្តាធិការសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាន ។ ដូច្នេះ ខ្ញុំបានរង់ចាំការពិភាក្សានាពេលព្រឹកមិញនេះដោយការចង់ដឹងបំផុតថាតើបញ្ហានេះនឹងវិវត្តទៅជាយ៉ាងណា ។

កិច្ចព្រមព្រៀងនាល្ងាចថ្ងៃពុធមុននេះមានខ្លឹមសារដូចតទៅ ៖

មាត្រា១៥ស្ទួនក្នុងការពិនិត្យផ្នែកទី២ចែងពីការអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មឈ្លានពាន ដែលមានមាត្រា១៣(ក) និង(គ)ជាយន្តការផ្ដើសេចក្ដីសម្រេច ។ នោះមានន័យថានៅពេលដែលប្រទេសជាភាគីណាមួយលើកឡើងពីកាលៈទេសៈរបស់(មាត្រា១៣(ក)) ឬនៅពេលដែលព្រះរាជអាជ្ញាផ្ដួចផ្ដើមការស៊ើបអង្កេតផ្ទាល់ ដោយទទួលបានសេចក្ដីអនុញ្ញាតពីអង្គបុរេជំនុំជម្រះ(មាត្រា១៣(គ)) នោះ ដំណើរការនេះនឹងជម្រុញឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិចាត់វិធានការណ៍ ។ សេចក្ដីព្រាងបានចែងដូចខាងក្រោម ៖

១. សម្រាប់ប្រទេសជាភាគីនីមួយៗដែលផ្ដល់សច្ចាប័នលើវិសោធនកម្មទាំងអស់ផ្នែកទី១៣(ក) និង(គ)ត្រូវតែធ្វើឡើងឲ្យឆាប់រហ័សបំផុតក្នុងរយៈពេល៥ឆ្នាំ បន្ទាប់ពីវិសោធនកម្មរបស់ប្រទេសជាភាគីនោះត្រូវបានដាក់ចូលជាធរមាន ។ នោះមានន័យថា យោងតាមមាត្រា១២១(៥) ប្រទេសជាភាគីទទួលបានរយៈពេល៦ឆ្នាំពេញក្នុងការដាក់វិសោធនកម្មចូលជាធរមាន ក្រោយពីបានផ្ដល់សច្ចាប័នរួច ។

២. បញ្ញត្តិលើលក្ខន្តិកៈយុត្តាធិការរបស់មាត្រា១៥ស្ទួននៅក្នុងការពិនិត្យឡើងវិញផ្នែកទី២ នៅតែមិនផ្លាស់ប្តូរ ដូចជាលក្ខន្តិកៈរបស់ក្រុមប្រឹក្សាសន្តិសុខដែលអនុវត្តទៅតាមលក្ខន្តិកៈរបស់អង្គបុរេជំនុំជម្រះ ។

៣. បន្ទាប់មកបញ្ហាប្រឈមមុខពិតប្រាកដនឹងចាប់ផ្ដើមឡើង ។ សេចក្ដីស្នើសុំនេះធ្វើការគូសបញ្ជាក់ពីបុរេលក្ខខណ្ឌរបស់មាត្រា១២ ស្ដីពីយុត្តាធិការសម្រាប់ប្រទេសជាភាគីដែលមានសិទ្ធិមួយចំនួន (ប្រទេសដែលបានផ្ដល់សច្ចាប័នលើវិសោធនកម្ម) ដូច្នេះសេចក្ដីស្នើសុំនេះនឹងមិនផ្លាស់ប្តូរអ្វីទៀតឡើយ ។ ប៉ុន្តែវានៅមានជម្រើសដែលមិនទទួលយកដែរ ដូចជាក្នុងករណីដែលប្រទេសជាភាគីបានចេញ«សេចក្ដីប្រកាស ស្ដីពីការមិនទទួលយកយុត្តាធិការរបស់តុលាការយោងតាមកថាខណ្ឌទី៤នៃមាត្រា១៥ស្ទួននេះ ។ បើករណីនេះកើតមានមែននោះវានឹងដាក់បញ្ចូលទស្សនៈរបស់មាត្រា១២១(៥)(អវិជ្ជមាន)ចូលទៅក្នុងមាត្រា១៥ស្ទួនថ្មីនេះ ។

៤. ការកំណត់រយៈពេលសម្រាប់ការចេញសេចក្ដីប្រកាសមួយដូចគ្នានេះ ដោយប្រទេសជាភាគីគឺពិតជាមានសារសំខាន់ ។ សេចក្ដីប្រកាសនេះត្រូវតែប្រគល់ឲ្យអគ្គរដ្ឋលេខាធិការអង្គការសហប្រជាជាតិមិនលើសពីថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១៥ឡើយ ។ ក្រោយពីកាលបរិច្ឆេទខាងលើនេះ ប្រទេសជាភាគីណាមួយដែលផ្ដល់សច្ចាប័ន ឬយល់ស្របតាមលក្ខន្តិកៈក្រុងរ៉ូមត្រូវតែ

ចេញសេចក្តីប្រកាសស្តីពីការមិនទទួលយកយុត្តាធិការរបស់តុលាការ នៅថ្ងៃដែលចេញសេចក្តីប្រកាស និងការព្រមព្រៀងនេះ ។

៥. សេចក្តីប្រកាសនេះ អាចនឹងត្រូវបានដកចេញវិញដោយប្រទេសជាភាគីបានគ្រប់ពេលវេលាទាំងអស់ ។ ការធ្វើដូច្នេះបានជម្រុញឲ្យយុត្តាធិការរបស់តុលាការកើតឡើងឆាប់រហ័សរវាងប្រទេសជាភាគីសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាន ។

៦. ចុងក្រោយបង្អស់ហើយសំខាន់ជាងនោះ គឺថាមានបញ្ញត្តិគន្លឹះមួយដែលតុលាការមិនត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មឈ្លានពានដូចដែលមានចែងនៅក្នុងមាត្រា (ដូចជា មាត្រាសម្រាប់សេចក្តីសម្រេចរបស់ប្រទេសជាភាគី និងដំណើរការស៊ើបអង្កេតផ្ទាល់របស់ព្រះរាជអាជ្ញា) ក្នុងករណីដែលឧក្រិដ្ឋកម្មឈ្លានពាននេះ ត្រូវបានប្រព្រឹត្តដោយប្រទេសមិនមែនជាភាគីឬប្រជាជនរបស់ប្រទេសមិនមែនជាភាគី ។

យើងទាំងអស់គ្នាបាននាំគ្នាត្រិះរិះពិចារណាលើសេចក្តីស្នើសុំដ៏មានប្រយោជន៍ និងឈ្លាសវៃនេះពេញមួយយប់ ។ ប៉ុន្តែសេចក្តីស្នើសុំនេះមិនទាន់ត្រូវបានពន្យល់បកស្រាយជាផ្លូវការដល់សន្និបាតស្តីពីការពិនិត្យវិសោធនកម្មឡើងវិញនោះទេ ដោយសារតែឯកសារក្រៅផ្លូវការរបស់លោកអគ្គរដ្ឋទូតវេណាវេសឺ អាចនឹងរៀបចំរួចរាល់អស់នៅព្រឹកថ្ងៃព្រហស្បតិ៍ ។

## ផ្នែកទីពីរ

នៅម៉ោង១១រសៀលថ្ងៃទី១០ ខែមិថុនា លោកអគ្គរដ្ឋទូត វេណាវេសឺ បានចែកជូនឯកសារក្រៅផ្លូវការថ្មីមួយស្តីពីឧក្រិដ្ឋកម្មឈ្លានពាន ។ ឯកសារក្រៅផ្លូវការនេះរួមបញ្ចូលផ្នែកខ្លះៗរបស់សេចក្តីស្នើសុំកាលពីល្ងាចថ្ងៃពុធដែរ ប៉ុន្តែវាមានលក្ខណៈខុសប្លែកពីគ្នាបន្តិចបន្តួច ។

ទីមួយ ឯកសារក្រៅផ្លូវការនេះបានបង្កើតជាជម្រើសសំខាន់ៗដែលវិសោធនកម្មគ្រប់បែបទាំងអស់ត្រូវតែត្រូតពិនិត្យដោយនីតិវិធីដាក់ចូលជាធរមានរបស់មាត្រា១២១(៥) ។ នេះគឺជាការបោះជំហានទៅមុខដ៏សំខាន់មួយ ពីព្រោះវាបានច្រានចោលលក្ខន្តិកៈទទួលស្គាល់វិសោធនកម្មរបស់មាត្រា១២១(៤) ដោយប្រទេសជាភាគីជាសម្លេងគាំទ្រប្រាំពីរលើប្រាំបី ។ ការធ្វើបែបនេះអាចមានន័យថា វិសោធនកម្មដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មឈ្លានពានអាចនឹងកើតមានឡើងនៅក្នុងលក្ខន្តិកៈក្រុងរ៉ូម (ដូចជាមាត្រា១៥) ហើយអាចនឹងស្ថិតនៅក្នុងវិសាលភាពរបស់នីតិវិធីលើវិសោធនកម្មនៃមាត្រា១២១(៥)សម្រាប់

សេចក្តីផ្តើមស្តីពីឧក្រិដ្ឋកម្មថ្មីៗ ។ ខ្ញុំមិនធ្វើការរៀបរាប់លក្ខន្តិកៈក្រុងរ៉ូមដោយគិតពីអ្វីដែលចាំបាច់ត្រូវធ្វើលើមាត្រាដែលមិនជាប់ពាក់ព័ន្ធនឹងលក្ខន្តិកៈក្រុងរ៉ូម រាល់ពេលដែលប្រទេសជាភាគីយល់ស្របធ្វើសេចក្តីណែនាំពីឧក្រិដ្ឋកម្មថ្មីមួយនោះទេ ប៉ុន្តែវាសមហេតុផលក្នុងការជំទាស់ថា ឧក្រិដ្ឋកម្មថ្មីទាំងឡាយណាអាចនឹងតម្រូវឲ្យផ្លាស់ប្តូរទៅតាមបញ្ញត្តិនៅក្នុងលក្ខន្តិកៈក្រុងរ៉ូម ដើម្បីបង្កើតជាឯកសារដែលផ្តល់ប្រយោជន៍ និងជាប់ពាក់ព័ន្ធគ្នាសម្រាប់ដំណើរប្រតិបត្តិការរបស់តុលាការ ។ បន្ថែមលើសនេះទៀតទស្សនៈប្រឆាំងអាចនឹងបរិយាយថាវិសោធនកម្មដែលមិនឋិតនៅក្នុងមាត្រា៥ ,៦ ,៧ឬ៨ អាចនឹងតម្រូវឲ្យស្របតាមនីតិវិធីរបស់មាត្រា១២១(៤) (ស្តីពីការអនុញ្ញាតឲ្យធ្វើវិសោធនកម្មដោយសម្លេងគាំទ្រប្រាំពីរលើប្រាំបីក្នុងចំណោមប្រទេសជាភាគី) ។

ទីពីរ ឯកសារក្រៅផ្លូវការនេះធ្វើការពិនិត្យឡើងវិញលើពាក្យដែលប្រើប្រាស់នៅក្នុងមាត្រា១៥ស្ទួនសម្រាប់ប្រទេសជាភាគី និងវិធានការយុត្តាធិការរបស់ព្រះរាជអាជ្ញាផ្ទាល់ដោយដាក់បញ្ចូលគំនិតខ្លះៗដែលបានលើកឡើងកាលពីល្ងាចថ្ងៃពុធ ប៉ុន្តែដោយប្រើប្រាស់ពាក្យផ្សេងគ្នា ។ ពាក្យថ្មីនោះបានចោទជាផលវិបាកមួយចំនួន ។ ស្ទួនទី១ថ្មីនៅក្នុងផ្នែកទី១នៃមាត្រា១៥ស្ទួនចែងដូចខាងក្រោម ប៉ុន្តែពាក្យដែលសរសេរនៅក្នុងវង់ក្រចកគឺជាពាក្យដែលខ្ញុំស្នើសុំឲ្យធ្វើការពិនិត្យឡើងវិញ : “ស្របតាមមាត្រា១២ តុលាការអាចអនុវត្តយុត្តាធិការរបស់ខ្លួនទាក់ទងនឹង(ឧក្រិដ្ឋកម្មឈ្លានពានដែលកើតចេញពី)សកម្មភាពឈ្លានពានដែលប្រព្រឹត្តដោយប្រទេសជាភាគី ប្រសិនបើប្រទេសនោះមិនបានចេញសេចក្តីប្រកាសមិនទទួលយក(យុត្តាធិការរបស់តុលាការលើឧក្រិដ្ឋកម្មឈ្លានពាន)ដល់អ្នកកាន់បញ្ជីឯកសារ” ។ បញ្ញត្តិនេះធ្វើការរក្សានូវបូរាណភាពនៃបុរេលក្ខខ័ណ្ឌរបស់មាត្រា១២ស្តីយុត្តាធិការ ប៉ុន្តែវាក៏បានសម្រេចទទួលយកប្រទេសជាភាគីមួយចំនួន ដែលជ្រើសរើសប្រកាសមិនទទួលយកយុត្តាធិការរបស់តុលាការសម្រាប់ឧក្រិដ្ឋកម្មឈ្លានពានដែរ ។ សេចក្តីចែងទាំងអស់នោះគឺឋិតនៅក្នុងទិសដៅដើមរបស់មាត្រា១២១(៥)ទាំងស្រុងតែម្តង ។ ជាមួយគ្នានេះ វាពិតជាចាំបាច់ក្នុងការចែងឲ្យច្បាស់ពីយុត្តាធិការរបស់តុលាការពីឧក្រិដ្ឋកម្មឈ្លានពានថាតើជនណាខ្លះដែលត្រូវនាំមកកាត់ទោស ប៉ុន្តែត្រឹមតែមិនមែនចែងពីឧក្រិដ្ឋកម្មឈ្លានពានដែលប្រព្រឹត្តដោយប្រទេសជាភាគី ហើយជួយញៀងតែពីយុត្តាធិការរបស់ឧក្រិដ្ឋកម្មឈ្លានពានប៉ុណ្ណោះទេ ។ ឯកសារក្រៅផ្លូវការនៅថ្ងៃព្រហស្បតិ៍ស្នើឲ្យមានផ្នែកទី១ស្ទួនថ្មីមួយនៅក្នុងផ្នែកទី១នៃមាត្រា១៥ស្ទួន ។ ផ្នែកថ្មីនេះមានចែងដូចតទៅ : “តុលាការមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនទាក់ទងនឹងឧក្រិដ្ឋកម្មឈ្លានពានដែលប្រព្រឹត្តដោយប្រទេសមិនមែនជាភាគីបានទេ” ។ ការប្រើប្រាស់ពាក្យនេះបានធ្វើឲ្យគណៈប្រតិភូក្តៅក្រហាយក្នុងចិត្ត ។ ទាក់ទងនឹងបញ្ហានេះវាហាក់ដូចជាផ្តល់ផលប្រយោជន៍

ឲ្យប្រទេសដែលមិនមែនជាភាគី ។ បញ្ហានេះបញ្ជាក់ថាប្រទេសមិនមែនជាភាគីទទួលបានការអនុញ្ញាតឲ្យប្រព្រឹត្តការឈ្លានពាន ។ តាមទស្សនៈរបស់ខ្ញុំ ការប្រើប្រាស់ភាសាដែលងាយយល់ជាងនេះនោះគឺថា ដោយត្រូវបានស្នើសុំឡើងនៅយប់ថ្ងៃពុធ ហើយដោយយោងតាមលក្ខខណ្ឌបន្ថែមប្រទេសមិនមែនជាភាគីទាំងឡាយណា ដែលមានបំណងមិនទទួលស្គាល់ពីការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មឈ្លានពានដែលយោងតាមលក្ខន្តិកៈក្រុងរ៉ូម នឹងត្រូវតែចុះហត្ថលេខាលើសេចក្តីប្រកាសមិនទទួលយកយុត្តាធិការរបស់តុលាការលើឧក្រិដ្ឋកម្មឈ្លានពាន ហើយត្រូវតែរក្សាទុកសេចក្តីប្រកាសនេះ ជាមួយនឹងអ្នកកាន់បញ្ជីជាសាធារណៈ ។ កត្តាដែលគួរឲ្យរអៀសខ្លួនតែមួយគត់នោះនឹងបង្ករឲ្យប្រទេសមិនមែនជាភាគីខ្លះផ្អាកសកម្មភាពរបស់ខ្លួន ។ ជំហានដូចនេះគួរតែឆ្លុះបញ្ចាំងឲ្យឃើញថាវាពិតមានសារសំខាន់ខាងផ្នែកនយោបាយសម្រាប់រដ្ឋាភិបាលដូចជាប្រទេសជប៉ុន ដែលខ្ញុំជឿថាប្រទេសនេះនឹងមិនអាចប្រកាសជូនសាធា-រណជនរបស់ខ្លួនពីវិសោធនកម្មនោះទេ ប្រសិនបើរដ្ឋាភិបាលជប៉ុនឲ្យប្រទេសកូរ៉េខាងជើងធ្វើដូចគ្នា ។ ជាងនេះទៅទៀត ប្រទេសកូរ៉េខាងជើងបានជួបប្រទះនឹងភាពអាម៉ាស់ជាសាធារណៈខ្លះដែរ ដែលបានបង្ខំឲ្យកូរ៉េខាងជើងចុះហត្ថលេខាលើសេចក្តីប្រកាសមិនទទួលស្គាល់យុត្តាធិការរបស់តុលាការ ពីការទទួលខុសត្រូវលើឧក្រិដ្ឋកម្មឈ្លានពាន ។

ដូចគ្នានឹងសិទ្ធិ និងបុព្វសិទ្ធិស្តីពី “Complementarity” តាមលក្ខន្តិកៈក្រុងរ៉ូម ប្រទេសមិនមែនជាភាគីត្រូវតែសហការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីទាញយកអត្ថប្រយោជន៍ពី “Complementa-rity” នេះឲ្យបានពេញលេញ ដើម្បីគេចចេញឲ្យផុតពីយុត្តាធិការរបស់តុលាការក្នុងកាលៈទេសៈជាក់លាក់ណាមួយ ។ ប្រហាក់ប្រហែលគ្នានេះដែរ ការតម្រូវឲ្យប្រទេសមិនមែនជាភាគីចេញសេចក្តីប្រកាសមិនទទួលយកយុត្តាធិការរបស់តុលាការ គឺជាសំណើរដ៏សមហេតុផលមួយសម្រាប់ជាប្រយោជន៍ដល់ការមិនជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវ ។

ដូច្នេះ ខ្ញុំធ្វើការពិចារណាលើផ្នែកទី១ស្ទួនដែលអាចនឹងត្រូវចែងថា : «ទាក់ទងនឹងប្រទេសមិនមែនជាភាគីរបស់លក្ខន្តិកៈនេះ តុលាការមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មឈ្លានពានដូចដែលមានចែងនៅក្នុងមាត្រានេះទេ ប្រសិនបើឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើងដោយប្រជាពលរដ្ឋ ឬនៅតាមព្រំប្រទល់ប្រទេសនោះ ។ ការទទួលបានបែបនេះអាចកើតមានឡើង លុះត្រាតែប្រទេសមិនមែនជាភាគីនោះ បានចេញសេចក្តីប្រកាសមិនទទួលស្គាល់យុត្តាធិការរបស់តុលាការលើឧក្រិដ្ឋកម្មឈ្លានពានដោយរក្សាទុកជាមួយនឹងអ្នកកាន់បញ្ជី ។

លេខយោងទី៤នៅក្នុងឯកសារក្រៅផ្លូវការ ធ្វើការលើកឡើងពីលទ្ធភាពរបស់សេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាសន្តិសុខតាមមាត្រា១៣(ខ) ថាជាមធ្យោបាយបន្ថែមមួយទៀតដើម្បីបង្កើនអំណាចរបស់ព្រះរាជអាជ្ញានៅក្នុងមាត្រា១៥ស្ទួន។ ខ្ញុំជឿថាទស្សនៈនេះគឺពិតជាសមហេតុផលឲ្យតែសេចក្តីបញ្ជាក់នេះក្លាយជាសេចក្តីថ្លែងការ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាលើសកម្មភាពឈ្លានពាន។ ដូច្នេះ ខ្ញុំសូមកែលម្អផ្នែកទី៣ឡើងវិញដើម្បីឲ្យមានន័យដូចខាងក្រោម (ដោយពាក្យថ្មីដែលឋិតនៅក្នុងវង់ដង្កៀប) ៖

«ខណៈពេលដែលក្រុមប្រឹក្សាសន្តិសុខបានធ្វើសេចក្តីសម្រេច (ឬបានបញ្ជាក់ពីស្ថានភាពនៃការឈ្លានពានជូនដល់ព្រះរាជអាជ្ញាយោងតាមផ្នែកទី១៣(ខ) នោះ ព្រះរាជអាជ្ញាអាចបន្តការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពានបាន» ។

សេចក្តីសម្រេចបន្ទាប់ទៀត ដែលបានគូសបញ្ជាក់នៅក្នុងឯកសារក្រៅផ្លូវការនេះគឺថា តើត្រូវបន្តរក្សាទុកដំណោះស្រាយទីមួយ ដែលនឹងមិនទទួលស្គាល់សិទ្ធិរបស់ព្រះរាជអាជ្ញាក្នុងការបន្តការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពាននោះឬយ៉ាងណា ប្រសិនបើក្រុមប្រឹក្សាសន្តិសុខមិនបានចេញសេចក្តីសម្រេច (ឬមិនមានការគូសបញ្ជាក់ពីសកម្មភាពឈ្លានពាន) ។ ដំណោះស្រាយទីមួយនេះទទួលបានការគាំទ្រតិចតួចណាស់នៅក្នុងការប្រជុំពិភាក្សាលើកមុន ។ ទោះបីជាដំណោះស្រាយនេះមានសារសំខាន់ដល់សមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខក្តី ក៏ខ្ញុំមិនមានការភ្ញាក់ផ្អើលដែរ ប្រសិនបើការប្រជុំពិភាក្សាលើកនេះសម្រេចជំនួសដំណោះស្រាយនេះដោយដំណោះស្រាយទីពីរ និងដោយអង្គបុរេជំនុំជម្រះវិញនៅថ្ងៃសុក្រនេះដែរ ។

ឯកសារក្រៅផ្លូវការនេះធ្វើការបញ្ជាក់ឡើងវិញពីការប្រើប្រាស់ពាក្យរបស់អង្គបុរេជំនុំជម្រះ ។ ខ្ញុំសូមស្នើសុំម្តងទៀតថាមធ្យោបាយមួយដើម្បីតម្រូវចិត្តរបស់សមាជិកអចិន្ត្រៃយ៍ខ្លះ និងដើម្បីគោរពតាមច្បាប់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងសារសំខាន់ចម្បងរបស់ក្រុមប្រឹក្សាសន្តិសុខនោះគឺត្រូវបន្ថែមពាក្យនៅផ្នែកចុងក្រោយនៃដំណោះស្រាយទីពីរឲ្យមានន័យថា «លុះត្រាតែក្រុមប្រឹក្សាសន្តិសុខធ្វើសេចក្តីសម្រេចដូច្នោះ» ឬ «លុះត្រាតែក្រុមប្រឹក្សាសន្តិសុខសម្រេចតាមការអនុម័តលើកិច្ចព្រមព្រៀងតាមជំពូក៧នៃច្បាប់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិដែលចែងថា ការស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឲ្យធ្វើឬផ្តួចផ្តើមឡើយ» ។ ការធ្វើបែបនេះនឹងជួយរក្សាតួនាទីផ្តល់«ការអនុញ្ញាត»របស់ក្រុមប្រឹក្សាសន្តិសុខក្នុងការចូលអន្តរាគមន៍ នៅពេលដែលអង្គបុរេជំនុំជម្រះចាប់ផ្តើម និងបញ្ចប់ដំណើរការនីតិវិធី ។ វិធានការបែបនេះតែម្យ៉ាងអាចផ្លួបផ្សំការអន្តរាគមន៍ពីសំណាក់ក្រុមប្រឹក្សាសន្តិសុខក្នុងឧក្រិដ្ឋ

កម្មឈ្លានពាន ទោះបីជាការធ្វើបែបនេះអាចស្តែងចេញជាលក្ខណៈអវិជ្ជមានក៏ដោយ ។ យ៉ាងហោចណាស់ ក្រុមប្រឹក្សាសន្តិសុខនឹងត្រូវបានជម្រុញឲ្យអន្តរាគមន៍ ប្រសិនបើបញ្ហានោះទាក់ទងនឹងដំណើរនីតិវិធីរវាងអង្គបុរេជំនុំជម្រះ និងព្រះរាជអាជ្ញា ។ នេះអាចបញ្ជាក់ឲ្យឃើញថាក្រុមប្រឹក្សាសន្តិសុខមិនមានអំណាចពេញសិទ្ធិទាក់ទិននឹងសេចក្តីសម្រេចរបស់តុលាការលើការឈ្លានពានទេ ប៉ុន្តែក្រុមប្រឹក្សានៅតែមានអំណាចសំខាន់ក្នុងការអន្តរាគមន៍ នៅពេលដែលក្រុមប្រឹក្សាសម្រេចធ្វើដូច្នោះ ។

ស្តីពីមាត្រា១៥ស្ទួនបន្ទាប់ដែលឆ្លុះបង្ហាញពីការអះអាងរបស់ក្រុមប្រឹក្សាសន្តិសុខវិញ ឯកសារក្រៅផ្លូវការនេះបានផ្តល់ជាជម្រើសមួយដើម្បីលុបចោលកថាខ័ណ្ឌបី និងប្រានចោលបញ្ញត្តិមូលដ្ឋានមួយចំនួនសម្រាប់ភាពចាំបាច់របស់ព្រះរាជអាជ្ញា ក្នុងការធ្វើសេចក្តីសម្រេចលើសកម្មភាពឈ្លានពានរបស់ក្រុមប្រឹក្សាសន្តិសុខ ។ តើការលុបចោលកថាខ័ណ្ឌខាងលើអាចកើតឡើងឬយ៉ាងណានោះ វាចាំបាច់ត្រូវតែមានការប្រើប្រាស់ពាក្យបន្ថែមទៀត ដើម្បីឆ្លុះបង្ហាញការពិតនៃការគូសបញ្ជាក់របស់មាត្រា១៣ (ខ) ។ ឧទាហរណ៍ ក្រុមប្រឹក្សាសន្តិសុខអាចធ្វើសេចក្តីសម្រេចលើការឈ្លានពានបាននៅក្នុងបរិបទកិច្ចព្រមព្រៀងរបស់ខ្លួន (មិនមែនសេចក្តីសម្រេចដោយឯកឯងនោះទេ) ។ ខាងក្រោមនេះគឺជាដំណោះស្រាយរបស់ខ្ញុំចំពោះបញ្ហានេះ ៖

នៅក្នុងផ្នែកទី១នៃមាត្រា១៥ស្ទួនបន្ទាប់ វាគួរតែកែលំអរឡើងវិញ (ជាមួយនឹងពាក្យថ្មីដែលឋិតនៅក្នុងវង់ដង្កៀប) ដូចតទៅ ៖ «តុលាការអាចអនុវត្តយុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មឈ្លានពានបានស្របតាមមាត្រា១៣(ខ) (និងបញ្ញត្តិរបស់មាត្រានេះ)» ។

ការធ្វើបែបនេះ អាចទាមទារឲ្យមានដាក់រួមគ្នារវាងយុត្តាធិការស្តីពីសិទ្ធិធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃមាត្រា១៣(ខ) និងចំណុចបន្ទាប់បន្សំដែលត្រូវបានគាក់តែងឡើងនៅក្នុងមាត្រា១៥ស្ទួនបន្ទាប់ ។

ដូច្នេះ ព្រះរាជអាជ្ញាអាចនឹងបន្តការស៊ើបអង្កេតយោងតាមលទ្ធភាពជាក់ស្តែងមួយក្នុងចំណោមលទ្ធភាពពីរខាងនេះ ៖ ១) ករណីដែលក្រុមប្រឹក្សាសន្តិសុខធ្វើសេចក្តីសម្រេចផ្ទុយពីកិច្ចព្រមព្រៀងនៃសេចក្តីសម្រេចតាមផ្នែកទី១៣(ខ) របស់ខ្លួនថា សកម្មភាពឈ្លានពានត្រូវបានប្រព្រឹត្តឡើង ។ ២) នៅក្នុងបរិបទធ្វើសេចក្តីសម្រេចលើកាលៈទេសៈរបស់ក្រុមប្រឹក្សាសន្តិសុខ ដែលមានចែងនៅក្នុងមាត្រា១៣(ខ) ស្តីពីការធ្វើសេចក្តីសម្រេច ។ ដូច្នេះ ផ្នែកទី៣នៃមាត្រា១៥ស្ទួនអាចមានន័យជាមួយនឹងពាក្យថ្មីដែលឋិតនៅក្នុងវង់ក្រចកថា ៖ «ខណៈពេលដែលក្រុមប្រឹក្សាសន្តិសុខបានធ្វើសេចក្តីសម្រេច ដូច្នេះ (ដែលមាននៅ

ក្នុងបរិបទធ្វើសេចក្តីសម្រេចលើកាលៈទេសៈរបស់ក្រុមប្រឹក្សាសន្តិសុខ ស្របតាមមាត្រា១៣(ខ) នោះ) ព្រះរាជអាជ្ញាអាចបន្តការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពាន» ។ ខ្ញុំគិតថាការធ្វើបែបនេះអាចជាវិធីដោះស្រាយដ៏ជាក់លាក់មួយដែលស្តីពីបញ្ហាដែលក្រុមប្រឹក្សាសន្តិសុខគួរតែធ្វើការ ដោះស្រាយនៅក្នុងសេចក្តីសម្រេចរបស់មាត្រា១៣(ខ) ។

## ផ្នែកទីបី

កាលពីល្ងាចថ្ងៃព្រហស្បតិ៍ ទី១០ ខែមិថុនា ឯកសារក្រៅផ្លូវការដែលត្រូវបានកែលំអរថ្មីរបស់លោកអគ្គរដ្ឋទូត វេណាវេសឺ ត្រូវបានចែកជូនគណៈប្រតិភូចូលរួមទាំងអស់ ។ នេះគឺជាឯកសារសំខាន់មួយដែលបានផ្តោះទៅរកដំណាក់កាលបញ្ចប់បញ្ហាទាំងប៉ុន្មានឲ្យបាននៅថ្ងៃសុក្រនេះ ។ វាធ្វើការឆ្លុះបង្ហាញឲ្យឃើញពីការពិភាក្សាទ្វេភាគីឥតឈប់ឈរដែលត្រូវបានធ្វើឡើងពេញមួយថ្ងៃព្រហស្បតិ៍ ។ ខ្ញុំយល់ថាឯកសារនេះគឺជាឯកសារដែលជួយជ្រោមជ្រែង ហើយខ្ញុំជឿថាឯកសារនេះបង្ហាញពីការប្តេជ្ញាធ្វើយ៉ាងណាឲ្យទទួលបាននូវលទ្ធផលដែលអាចទទួលយកបានជាទូទៅនៅថ្ងៃសុក្រនេះ ប៉ុន្តែសេចក្តីសម្រេចសំខាន់ៗនឹងត្រូវធ្វើឡើងជាបណ្តោះអាសន្នតែប៉ុណ្ណោះ ។

ដំណោះស្រាយព្រាងដែលសម្រេចអនុម័តវិសោធនកម្មលើការឈ្លានពាន នៅក្នុងកថាខ័ណ្ឌសំខាន់ទី១នៃដំណោះស្រាយនោះឆ្លុះបង្ហាញថា សេចក្តីសម្រេចកំពុងតែត្រូវបានធ្វើឡើងយោងតាមមាត្រា៥(ខ) នៃលក្ខន្តិកៈក្រុងរ៉ូម ។ នោះគឺជាការគូសបញ្ជាក់បច្ចេកទេសមួយ ។

ការពិនិត្យឡើងវិញបន្ទាប់ទៀតក៏ធ្វើឡើងនៅក្នុងកថាខ័ណ្ឌសំខាន់ទី១ដែរ ហើយវាបញ្ជាក់ថាការប្រកាសមិនទទួលយកយុត្តាធិការរបស់តុលាការលើឧក្រិដ្ឋកម្មឈ្លានពានតាមមាត្រា១៥ស្ទួនរបស់ប្រទេសជាភាគីត្រូវតែធ្វើឡើងមុនការផ្តល់សច្ចាប័ន ឬការទទួលយកវិសោធនកម្មរបស់ប្រទេសជាភាគីនោះទៅតាមច្បាប់ និងនីតិវិធីក្នុងប្រទេសរបស់ខ្លួន ។ ការធ្វើបែបនេះតម្រូវឲ្យប្រទេសជាភាគីគោរពតាមវិន័យត្រឹមត្រូវមួយ ដែលគូសបញ្ជាក់យ៉ាងច្បាស់ពីពេលវេលាដែលប្រទេសជាភាគីត្រូវប្រគល់ជូនសេចក្តីប្រកាសដើម្បីគេចចេញពីយុត្តាធិការរបស់តុលាការទាក់ទិននឹងវិសោធនកម្ម ។ វាមានលក្ខណៈស្របគ្នានឹងបុព្វសិទ្ធិចេញសេចក្តីប្រកាស សម្រាប់ប្រទេសដែលមិនមែនជាភាគីយោងតាមមាត្រា១២(៣) នៃលក្ខន្តិកៈក្រុងរ៉ូម ។ ជាមួយគ្នានេះ សេចក្តីប្រកាសមិនទទួលយកយុត្តាធិការរបស់តុលាការអាចនឹងរក្សាទុក

ជាមួយនឹងរដ្ឋាបាលកាន់បញ្ជី ក្រោយពេលដែលប្រទេសជាភាគីបានផ្តល់សច្ចាប័នលើវិសោធនកម្មលើខក្រិដ្ឋកម្មឈ្លានពានយោងតាមផ្នែកទី១ស្ទួនថ្មីនៃមាត្រា១៥ស្ទួន ។ ប៉ុន្តែ សេចក្តីប្រកាសនេះត្រូវតែបានរក្សាទុក មុនពេលដែលខក្រិដ្ឋកម្មឈ្លានពានដែលកើតចេញពីសកម្មភាពឈ្លានពានត្រូវបានប្រព្រឹត្តឡើងដោយប្រទេសជាភាគីនោះ ។ ដូច្នេះ យោងតាមការប្រព្រឹត្តខក្រិដ្ឋកម្ម សេចក្តីប្រកាសមិនទទួលយកយុត្តាធិការដែលយឺតមិនអាចដាក់ចូលជាធរមានបានឡើយ ។

បន្ថែមលើនេះ ឯកសារក្រៅផ្លូវការនេះគូសបង្ហាញពីការកែលំអរពាក្យពេចន៍សំខាន់ៗមួយចំនួនរបស់មាត្រា១៥ស្ទួនដែលទាក់ទងពីការអនុវត្តយុត្តាធិការរបស់តុលាការលើខក្រិដ្ឋកម្មឈ្លានពាន នៅក្នុងករណីដែលប្រទេសជាភាគី ឬព្រះរាជអាជ្ញាផ្តួចផ្តើមធ្វើការស៊ើបអង្កេតផ្ទាល់ដោយមានការអនុញ្ញាតពីអង្គបុរេជំនុំជម្រះ ។

ផ្នែកទី១ស្ទួនថ្មីនៃមាត្រា១៥ស្ទួនចែងថា : «តុលាការអាចអនុវត្តយុត្តាធិការរបស់ខ្លួនបានតែក្នុងករណីដែលខក្រិដ្ឋកម្មឈ្លានពានត្រូវបានប្រព្រឹត្តឡើងក្នុងរយៈពេលប្រាំឆ្នាំ បន្ទាប់ពីសេចក្តីអនុម័តលើវិសោធនកម្មពីខក្រិដ្ឋកម្មឈ្លានពាន ហើយក្នុងរយៈពេលមួយឆ្នាំ ក្រោយពីការផ្តល់សច្ចាប័ន ឬការទទួលស្គាល់វិសោធនកម្មដោយប្រទេសជាភាគីចំនួន៣០» ។ ការចែងនេះធ្វើការឆ្លើយតបនឹងការសង្កត់ធ្ងន់របស់គណៈប្រតិភូដែលសំណូមពរឲ្យមានការពន្យាពេលមួយរយៈសម្រាប់ការសម្រេចចិត្ត មុននឹងខក្រិដ្ឋកម្មឈ្លានពានត្រូវបានដាក់ចូលជាធរមាន ហើយបានបង្កើតជាវិធានពីរសម្រាប់ការពន្យារពេលនោះ ។ វិធានទីមួយគឺមានរយៈពេលប្រាំឆ្នាំក្រោយពេលសន្និបាតពិនិត្យឡើងវិញនេះបញ្ចប់ទៅ ដោយសន្មត់ថាវិសោធនកម្មត្រូវបានអនុម័តត្រឹមថ្ងៃសុក្រ ហើយនៅក្នុងឆ្នាំ២០១៥ ។ ដូច្នេះ ការដាក់ចូលជាធរមាននៃខក្រិដ្ឋកម្មឈ្លានពាននឹងមិនអាចសម្រេចធ្វើឡើងដោយប្រទេសជាភាគី ឬសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាផ្ទាល់មុនឆ្នាំ២០១៥នោះទេ ។ ការសន្មត់ខាងលើនេះមានលក្ខណៈគោរពទៅតាមទស្សនៈមុនៗ លក្ខខណ្ឌិកៈបន្ថែមនៃចំនួនប្រទេសជាភាគីទាំង៣០ដែលបានផ្តល់សច្ចាប័ន ឬទទួលស្គាល់វិសោធនកម្មគឺជាការសម្រុះសម្រួលដ៏សំខាន់មួយរវាងគណៈប្រតិភូចូលរួមទាំងអស់ ដើម្បីដាក់ខក្រិដ្ឋកម្មឈ្លានពានចូលជាធរមានបានលុះត្រាតែចំនួនប្រទេសជាភាគីដែលមានលក្ខណៈគ្រប់គ្រាន់ត្រូវបានដាក់បញ្ចូលជាមុនសិន ។ ការធ្វើបែបនេះពិតជាមានសារសំខាន់ ពីព្រោះនីតិវិធីវិសោធនកម្មត្រូវគោរពតាមមាត្រា១២១(៥) ដើម្បីដាក់វិសោធនកម្មចូលជាធរមាន ជាងមាត្រា១២១(៤) (ដែលតម្រូវឲ្យមានការផ្តល់សច្ចាប័នពីចំណោមប្រទេសជាភាគីជាសម្លេងគាំទ្រប្រាំពីរលើប្រាំបីដើម្បីដាក់វិសោធនកម្មចូលជាធរមាន) ។ ចំនួន

ប្រទេសជាភាគីតែ៣០ អាចនឹងមានលក្ខណៈមិនស្មើភាព ហើយវាទំនងជាគួសបញ្ជាក់ពីមាត្រា១២១(៥) ប៉ុន្តែវាក៏ធ្វើការឆ្លុះបញ្ចាំងជាដំណោះស្រាយដែលអាចធ្វើទៅបានដែរ ។

បន្ទាប់មកទៀត ឯកសារក្រៅផ្លូវការនេះធ្វើការស្នើសុំឲ្យមានការពិនិត្យលើផ្នែកទី១ស្ទួនឡើងវិញជាបន្ត បន្ទាប់សម្រាប់មាត្រា១៥ស្ទួន ។ វាចែងដូចតទៅ ៖ “ស្របតាមមាត្រា១២ តុលាការអាចអនុវត្ត យុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មឈ្លានពាន ដែលកើតចេញពីសកម្មភាពឈ្លានពានដែលប្រព្រឹត្តដោយ ប្រទេសជាភាគីមួយបាន លុះត្រាតែប្រទេសជាភាគីនោះបានប្រកាសថាខ្លួនមិនទទួលយកយុត្តាធិការ របស់តុលាការដោយរក្សាទុកសេចក្តីប្រកាសនេះជាមួយនឹងរដ្ឋបាលកាន់បញ្ជីជាមុនសិន ។ ការដកយក សេចក្តីប្រកាសនេះវិញអាចធ្វើឡើងដោយមានប្រសិទ្ធភាពគ្រប់ពេលវេលាទាំងអស់ ប៉ុន្តែត្រូវតែមាន ការពិចារណាដោយប្រទេសជាភាគីក្នុងរយៈពេលបីឆ្នាំសិន” ។

ដំបូង ផ្នែកទី១ស្ទួនធ្វើការគូសបញ្ជាក់ថាយុត្តាធិការរបស់តុលាការគឺមានដែនសមត្ថកិច្ចលើឧក្រិដ្ឋកម្ម ឈ្លានពាន ប៉ុន្តែចំពោះតែឧក្រិដ្ឋកម្មដែលកើតចេញពីសកម្មភាពឈ្លានពានដែលប្រព្រឹត្តដោយប្រទេស ជាភាគីប៉ុណ្ណោះ ។ នេះគឺជាលក្ខណៈខុសគ្នាដ៏សំខាន់មួយ ពីព្រោះតុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើការកាត់ ទោសបុគ្គល មិនមែនប្រទេសជាភាគីនោះទេ ។ បញ្ហានេះនឹងវិលទៅរកការបកស្រាយម្តងទៀតថាតើ សកម្មភាពអ្វីខ្លះដែលចាត់ទុកថាជាសកម្មភាពឈ្លានពាន និងឧក្រិដ្ឋកម្មឈ្លានពាន ។

ដូច្នេះ វាក៏មានជាសិទ្ធិមិនចូលរួមសម្រាប់ប្រទេសជាភាគីក្នុងការចេញសេចក្តីប្រកាសមិនទទួលស្គាល់ យុត្តាធិការរបស់តុលាការសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាន ។ ឯកសារក្រៅផ្លូវការនេះ ធ្វើការឆ្លុះបញ្ចាំង ការពិតដែលថា ការមិនទទួលស្គាល់យុត្តាធិការរបស់តុលាការ ត្រូវតែពន្យល់បកស្រាយដោយសេចក្តី ប្រកាសជាលាយល័ក្ខអក្សរដែលរក្សាទុកនឹងរដ្ឋបាលកាន់បញ្ជីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែល ការធ្វើដូច្នេះនឹងក្លាយជាទង្វើដ៏ស្អាតស្អំជាសាធារណៈមួយ ។ ប្រទេសជាភាគីមួយចំនួនអាចនឹងមិនចង់ឲ្យ គេឃើញថាខ្លួនបានធ្វើសកម្មភាពដែលបង្ករឿងហេតុចម្បងបែបនេះទេ ដូច្នេះវាក៏ជារឿងអាម៉ាស់ក្នុង ការបំពេញធ្វើបែបនេះ ។ យ៉ាងណាមិញ ជម្រើសនេះឆ្លុះបញ្ចាំងពីនីតិវិធីមិនចូលរួម ដែលមានចែងនៅ ក្នុងមាត្រា១២១(៥) ដូច្នេះវាត្រូវតែជាផ្នែកមួយនៃភាពស្មើគ្នា ។

ចុងក្រោយបង្អស់ តាមអនុសញ្ញាវៀនណាស្តីពីច្បាប់សន្ធិសញ្ញា ផ្នែកទី១ស្ទួនបង្កើតជាចំណុចដ៏ជាក់លាក់ មួយដែលថា សេចក្តីប្រកាសនៃការមិនទទួលស្គាល់អាចដកចេញបានដោយប្រទេសជាភាគីគ្រប់ពេល វេលាទាំងអស់ ។ ការធ្វើបែបនេះអាចជម្រុញឲ្យមានការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាន

សម្រាប់ប្រជាជនរបស់ប្រទេសជាភាគីនោះ ។ ប៉ុន្តែ ផ្នែកទី១ស្ទួននេះតម្រូវឲ្យប្រទេសជាភាគីដែលបាន ចេញសេចក្តីប្រកាសមិនទទួលស្គាល់យុត្តាធិការរបស់តុលាការ ធ្វើការពិចារណាដកចេញសេចក្តីប្រកាសរបស់ខ្លួនក្នុងរយៈពេលបីឆ្នាំ ។ នេះគឺជាការស្នើសុំដោយនីតិវិធីដ៏តឹងរ៉ឹងមួយ ប៉ុន្តែប្រទេសជាភាគីគួរតែមិនមានភារៈកិច្ចចាំបាច់អ្វី ដើម្បីដកចេញសេចក្តីប្រកាសនោះដែរ ។

មួយភាគបួននៃផ្នែកទី១ថ្មីចែងថា : «ទាក់ទិននឹងប្រទេសដែលមិនមែនជាភាគីរបស់លក្ខន្តិកៈក្រុងរ៉ូម តុលាការមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួន លើឧក្រិដ្ឋកម្មឈ្លានពានដែលប្រព្រឹត្តដោយប្រជាជន ឬតាមព្រំប្រទល់របស់ប្រទេសនោះបានទេ» ។ ពាក្យនេះគឺពិតជាមានសារសំខាន់សម្រាប់ការគាំទ្រដល់ប្រទេសមិនមែនជាភាគីដែលចូលរួមនៅក្នុងសន្និបាតពិនិត្យឡើងវិញនេះ ហើយវាក៏បានកែសម្រួលភាពចម្រូងចម្រាស់នៅក្នុងមាត្រា១២១(៥) ដែលដោះស្រាយតែបញ្ហាបុព្វសិទ្ធិរបស់ប្រទេសជាភាគីក្នុងការមិនចូលរួមពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មថ្មី ខណៈពេលដែលទុកឲ្យប្រទេសមិនមែនជាភាគីប្រឈមមុខនឹងការទទួលខុសត្រូវចម្បងសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាននោះ ។

ខ្ញុំគិតថា ខណៈពេលដែលឧក្រិដ្ឋកម្មថ្មីត្រូវបានពិចារណានាពេលខាងមុខ គោលការណ៍នៃការមិនចូលរួមពីសំណាក់ប្រទេសមិនមែនជាភាគីនឹងអាចកើតឡើងម្តងទៀត ។ ប៉ុន្តែគួរឲ្យចាប់អារម្មណ៍ផងដែរថា ភាពសមហេតុផលនេះមិនបានបញ្ចប់ការអនុម័តលើបញ្ហាអាវុធ ដែលត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់សម្រាប់ជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ ដែលមានចែងនៅក្នុងវិសោធនកម្មលើមាត្រា ៨ ដូចជាការប្រើប្រាស់ជាតិពុល អាវុធដែលមានជាតិពុល ផ្សែងពុល ឬសារធាតុផ្សេង និងគ្រាប់កាំភ្លើងធំ ដែលត្រូវបានអនុម័តកាលពីល្ងាចថ្ងៃព្រហស្បតិ៍ដែលជាវិសោធនកម្មលក្ខណៈប្រវត្តិសាស្រ្តដំបូងនៅក្នុងលក្ខន្តិកៈក្រុងរ៉ូមទេ ។ វិសោធនកម្មនោះមិនបង្កើតជាការសម្រុះសម្រួលច្បាស់លាស់ដល់ប្រទេសមិនមែនជាភាគីទេ ដូច្នេះវិសោធនកម្មនេះមិនមានគោលបំណងកែសម្រួលមាត្រា១២១(៥) ស្តីពីការប្រើប្រាស់អាវុធថ្មីខាងលើទាំងអស់នេះ សម្រាប់ជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិនោះទេ ។ គ្មានគណៈប្រតិភូណាមួយបានលើកឡើងពីការជំទាស់របស់ខ្លួនចំពោះការមិនដាក់បញ្ចូលអាវុធទាំងនេះឡើយនាយប់នេះ ។ ខ្ញុំអាចយល់ពីមូលហេតុក្នុងការធ្វើដូច្នេះត្រង់ថា អាវុធទាំងនេះ ត្រូវបានបញ្ចូលក្នុងមាត្រា៨(២)(ខ) សម្រាប់ជម្លោះប្រដាប់អាវុធលក្ខណៈអន្តរជាតិរួចហើយ ដូច្នេះទើបគ្មាននរណាម្នាក់លើកឡើងការមិនយល់ស្របរបស់ខ្លួនឡើយ ។ ហើយវិសោធនកម្មនេះ គឺជាការពង្រីកការហាមឃាត់កុំឲ្យប្រើប្រាស់អាវុធដ៏សមហេតុផលមួយ សម្រាប់ជម្លោះប្រដាប់អាវុធ ដែលមិនមែនជាលក្ខណៈអន្តរជាតិ ។ ដូច្នេះអាវុធទាំងអស់នេះគ្រាន់តែត្រូវបានចាត់ទុកថាជាអាវុធ«ថ្មី» ជាងអាវុធដែល

ត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់អស់រយៈពេលយ៉ាងយូរ នៅក្នុងលក្ខន្តិកៈក្រុងរ៉ូម ដែលត្រូវបានដាក់ចូលក្នុងលទ្ធភាពបន្ថែមមួយទៀតទាក់ទិននឹងជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ ។

ឯកសារក្រៅផ្លូវការនេះបានធ្វើការបកស្រាយពីដំណោះស្រាយសំខាន់ទាំងពីរសម្រាប់លក្ខន្តិកៈយុត្តាធិ-ការចុងក្រោយ នៅពេលដែលមានសេចក្តីសម្រេចរបស់ប្រទេសជាភាគីនិងដំណើការស៊ើបអង្កេតដោយផ្ទាល់ពីសំណាក់ព្រះរាជអាជ្ញាត្រូវបានធ្វើឡើង ។ ដំណោះស្រាយទី១ដែលធ្វើការបញ្ឈប់ដំណើរការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញានឹងរក្សាទុក ប្រសិនបើគ្មានសេចក្តីសម្រេចឲ្យធ្វើពីសំណាក់ក្រុមប្រឹក្សាសន្តិសុខទាក់ទិននឹងសកម្មភាពឈ្លានពាន ដែលប្រព្រឹត្តដោយប្រទេសដែលពាក់ព័ន្ធនឹងរឿងនេះ ។ ការប្រើប្រាស់ពាក្យថ្មីមានសេចក្តីដូចតទៅ : “(ដំណោះស្រាយទី១) ក្នុងករណីដែលគ្មានសេចក្តីសម្រេចដូចខាងលើព្រះរាជអាជ្ញាមិនអាចបន្តការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពានបានទេ ប្រសិនបើក្រុមប្រឹក្សាសន្តិសុខមិនបានសំណូមពរឲ្យព្រះរាជអាជ្ញាបន្តដំណើរការស៊ើបអង្កេត ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលអនុម័តក្រោមជំពូក៧នៃច្បាប់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ” ។

ពាក្យនៅក្នុងវង់ដង្កៀបថ្មីបានឆ្លុះបង្ហាញពីលទ្ធភាពដែលថា ក្រុមប្រឹក្សាសន្តិសុខអាចបញ្ជូនរឿងក្តីស្នើឲ្យព្រះរាជអាជ្ញាបន្តធ្វើការស៊ើបអង្កេត ។ ការធ្វើបែបនេះពិតជាមានប្រយោជន៍ ពីព្រោះថាវាមិនត្រឹមតែអនុញ្ញាតឲ្យមានការធ្វើសេចក្តីសម្រេចថា សកម្មភាពឈ្លានពានបានកើតឡើងប៉ុណ្ណោះទេ (ដែលក្រុមប្រឹក្សាសន្តិសុខកម្រនឹងធ្វើសេចក្តីសម្រេចបែបនេះណាស់) វាថែមទាំងអនុញ្ញាតឲ្យក្រុមប្រឹក្សាសន្តិសុខធ្វើការចាត់ចែងឲ្យព្រះរាជអាជ្ញាបំពេញកិច្ចការស៊ើបអង្កេតរបស់ខ្លួនលើរឿងក្តី ដែលយើងអាចជឿថាវានឹងឈានទៅរកការចោទប្រកាន់លើបុគ្គលពីបទឧក្រិដ្ឋកម្មឈ្លានពានបាន ។ ប៉ុន្តែ នៅត្រង់ចំណុចនេះក៏មិនមានភាពច្បាស់លាស់នៅឡើយដែរ ដោយសារតែការប្រើប្រាស់ពាក្យថ្មីនោះមិនបានតម្រូវឲ្យកិច្ចព្រមព្រៀងរបស់ក្រុមប្រឹក្សាសន្តិសុខអះអាងថាសកម្មភាពឈ្លានពានបានកើតមានឡើង ឬក៏រៀបរាប់ពីស្ថានភាពទាក់ទិននឹងឧក្រិដ្ឋកម្មសាហាវឃោរឃៅដែលបង្កើតជាឧក្រិដ្ឋកម្មឈ្លានពោនទេ ។ ប៉ុន្តែ ខ្ញុំអានហើយយល់ឃើញថាវាមានន័យថា ក្រុមប្រឹក្សាសន្តិសុខត្រូវតែគូសបញ្ជាក់នៅក្នុងអត្ថបទរបស់កិច្ចព្រមព្រៀងជំពូក៧ថាតើព្រះរាជអាជ្ញាត្រូវតែធ្វើការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពានឬយ៉ាងណា ។

ដំណោះស្រាយទី១ ដែលឥឡូវនេះ ត្រូវបានព្រៀងឡើងដោយភ្ជាប់ជាមួយនឹងពាក្យនៅក្នុងវង់ដង្កៀបនោះគឺជាការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់មួយ ហើយបានជម្រុញលើកទឹកចិត្តដល់សមាជិកអចិន្ត្រៃរបស់ក្រុមប្រឹក្សាសន្តិសុខ ។ តាមពិតទៅ ដំណោះស្រាយទី១ត្រូវបានរក្សាទុក មុនសន្និបាតពិនិត្យឡើងវិញ

បានធ្វើឡើងរហូតដល់ថ្ងៃសុក្រ ។ ខ្ញុំនៅតែមានមន្ទិលសង្ស័យថា ការកែលំអពាក្យថ្មីបែបនេះ អាចនឹងធ្វើឲ្យមានការផ្លាស់ប្តូរកើតឡើង លើដំណោះស្រាយទី២ ដែលមានការបដិសេធពីសំណាក់គណៈប្រតិភូកាលពីប៉ុន្មានថ្ងៃមុនដែរឬទេ ។ ប៉ុន្តែយើងគួរតែរង់ចាំមើលបន្តទៀត ។

ដំណោះស្រាយទី២ត្រូវបានកែលំអឡើងវិញនៅក្នុងឯកសារក្រៅផ្លូវការដើម្បីកំណត់ថា សិទ្ធិក្នុងការសម្រេចឲ្យមានការចាប់ផ្តើមដំណើរការស៊ើបអង្កេត ដោយព្រះរាជអាជ្ញាត្រូវតែទទួលផ្តល់ឲ្យដោយអង្គភាពអង្គបុរេជំនុំជម្រះ ។ ការពិនិត្យកែលំអនេះឆ្លុះបង្ហាញពីសេចក្តីស្នើសុំកាលពីមុនមួយដែលមានចែងនៅក្នុងលេខឯកសារយោងមួយ ។ វាគួរតែលាតត្រដាងពីភាពមន្ទិលសង្ស័យលើដំណោះស្រាយទី២នោះ ដោយតម្រូវឲ្យចៅក្រមមួយចំនួនធំធ្វើការយល់ស្របលើការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញាលើឧក្រិដ្ឋកម្មឈ្លានពាន ក្នុងករណីដែលក្រុមប្រឹក្សាសន្តិសុខមិនបានចេញសេចក្តីសម្រេច ។

ជាមួយគ្នានេះ ដំណោះស្រាយទី២បានបញ្ចូលអនុប្រយោគដែលឋិតនៅក្នុងវង់ដង្កៀបចុងក្រោយមួយដែលអនុញ្ញាតឲ្យមានការស៊ើបអង្កេតពីសំណាក់ព្រះរាជអាជ្ញា (ដែលផ្តល់សិទ្ធិដោយអង្គភាពអង្គបុរេជំនុំជម្រះ) លុះត្រាតែក្រុមប្រឹក្សាសន្តិសុខមិនបានសម្រេចលើបញ្ហានេះ ។ បញ្ញត្តិមានន័យថា : “(ដំណោះស្រាយទី២) នៅពេលដែលសេចក្តីសម្រេចត្រូវបានធ្វើឡើងក្នុងរយៈពេលប្រាំមួយខែក្រោយ ពីកាលបរិច្ឆេទនៃការទទួលស្គាល់នោះ ព្រះរាជអាជ្ញាអាចបន្តដំណើរការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពានឲ្យតែអង្គភាពអង្គបុរេជំនុំជម្រះ បានផ្តល់សិទ្ធិអនុញ្ញាតឲ្យចាប់ផ្តើមការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពានស្របតាមនីតិវិធីដែលមាននៅក្នុងមាត្រា១៥ (ហើយក្រុមប្រឹក្សាសន្តិសុខមិនបានសម្រេចអ្វីសោះ)” ។

អនុប្រយោគដែលឋិតនៅក្នុងវង់ដង្កៀប គឺជា“ការមិនអនុញ្ញាត” ដែលមិនឲ្យក្រុមប្រឹក្សាសន្តិសុខ “សម្រេច”ឲ្យការស៊ើបអង្កេតចាប់ផ្តើមដំណើរការបន្តទៀតឡើយ ។ ទម្រង់នៃសេចក្តីសម្រេចនៅតែមិនមានលក្ខណៈច្បាស់លាស់នៅឡើយទេ ដែលតម្រូវឲ្យមានភាពបត់បែនតាមកាលៈទេសៈពីក្រុមប្រឹក្សាសន្តិសុខនាពេលអនាគត ។ នេះគឺជាបញ្ញត្តិសម្រុះសម្រួលដ៏មានប្រយោជន៍មួយដែលអាចកាត់បន្ថយភាពខុសគ្នាដែលមាននៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាសន្តិសុខ ។ ពាក្យនៅក្នុងវង់ដង្កៀបគូសបញ្ជាក់ពីសារសំខាន់របស់ក្រុមប្រឹក្សាសន្តិសុខទាក់ទិននឹងបញ្ហាឈ្លានពាន ប៉ុន្តែវាក៏ធ្វើមានការប៉ះពាល់ដល់តួនាទីរបស់អង្គភាពអង្គបុរេជំនុំជម្រះ ។ យ៉ាងណាមិញ វាក៏បានទទួលស្គាល់ថាក្រុមប្រឹក្សាសន្តិសុខមិនមានសិទ្ធិដាច់មុខទាក់ទិននឹងការឈ្លានពាននោះទេ (ជាពិសេសទាក់ទិននឹងបញ្ហាតុលាការ) ។ នេះគឺជាចំណុច

ដែលគណៈប្រតិភូជាច្រើននាក់បានធ្វើការសង្កត់ធ្ងន់ ហើយការពិនិត្យឡើងវិញនេះជួយសម្របសម្រួលទស្សនៈនោះ ហើយស្របពេលជាមួយគ្នានេះធ្វើការការពារសមភាពរបស់ក្រុមប្រឹក្សាសន្តិសុខ ។

មាត្រា១៥ស្ទួនថ្មី ដែលមានចែងពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខយោងតាមមាត្រា១៣(ខ) នៃលក្ខន្តិកៈក្រុងរ៉ូមត្រូវបានពន្យល់បកស្រាយយ៉ាងលម្អិត ។ គោលការណ៍ស្នូលដែលគួរឲ្យចងចាំនៅត្រង់នេះគឺថាក្រុមប្រឹក្សាត្រូវតែអនុម័តតាមកិច្ចព្រមព្រៀងជំពូក៧ ដើម្បីបញ្ជូនរឿងក្តីទាក់ទងពីការឈ្លានពានទៅកាន់ព្រះរាជអាជ្ញា ហើយក្នុងករណីដែលក្រុមប្រឹក្សាសម្រេចធ្វើដូច្នេះមែននោះ ក្រុមប្រឹក្សាសន្តិសុខ អាចរួមបញ្ចូលមិនមែនត្រឹមតែប្រទេសជាភាគីដែលបានផ្តល់សច្ចាប័នលើវិសោធនកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រទេសជាភាគីដែលមិនបានផ្តល់សច្ចាប័នលើវិសោធនកម្ម និងប្រទេសមិនមែនជាភាគីផងដែរ ។

ផ្នែកអនុវត្តទី២នៃមាត្រា១៥ស្ទួនមានន័យដូចតទៅ : “តុលាការអាចអនុវត្តយុត្តាធិការបានតែលើឧក្រិដ្ឋកម្មឈ្លានពាន ដែលត្រូវបានប្រព្រឹត្តឡើងក្នុងរយៈពេលយ៉ាងហោចណាស់ប្រាំឆ្នាំក្រោយពីការអនុម័តលើវិសោធនកម្មលើឧក្រិដ្ឋកម្មឈ្លានពាន និងរយៈពេលមួយឆ្នាំក្រោយពីការផ្តល់សច្ចាប័ន ឬការទទួលយកវិសោធនកម្មដោយប្រទេសជាភាគីចំនួន៣០តែប៉ុណ្ណោះ” ។ បញ្ញត្តិនេះធ្វើការឆ្លុះបញ្ចាំងពីបញ្ហាដែលកិច្ចព្រមព្រៀងនេះ នឹងបញ្ជាក់ជូននៅក្នុងកថាខ័ណ្ឌអនុវត្តទី១ទាក់ទិននឹងការបង្កើតជាការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាន ។

ដូច្នេះ មាត្រា១៥ស្ទួនមិនតម្រូវឲ្យមានសេចក្តីសម្រេចដាច់ដោយឡែកមួយលើសកម្មភាពឈ្លានពានដោយក្រុមប្រឹក្សាសន្តិសុខ ដូចដែលកិច្ចព្រមព្រៀងលើសេចក្តីសម្រេចក្នុងជំពូក៧ធ្វើការដោះស្រាយចំណុចនោះ ។ ក្រុមប្រឹក្សាសន្តិសុខអាចធ្វើតាមអ្វីដែលខ្លួនជ្រើសរើស ប៉ុន្តែប្រសិនបើក្រុមប្រឹក្សាសន្តិសុខអនុម័តកិច្ចព្រមព្រៀងដូច្នេះនោះ ក្រុមប្រឹក្សាសន្តិសុខអាចចាត់ទុកកិច្ចព្រមព្រៀងនោះជាវិធានការនៃមាត្រា១៣(ខ) ដើម្បីបញ្ជូនរឿងក្តីទាក់ទិននឹងការឈ្លានពានទៅកាន់ព្រះរាជអាជ្ញា ។

ចុងក្រោយនេះ ផ្នែកបន្ថែមទី៣លើកិច្ចព្រមព្រៀងដែលរួមបញ្ចូលទាំងកិច្ចព្រមព្រៀងលើវិសោធនកម្មធ្វើការលើកឡើងពីអាជ្ញាយុកាលរបស់ប្រទេសជាភាគីទាំង៣០ និងអាជ្ញាយុកាលដែលមានរយៈពេលប្រាំឆ្នាំនៅក្នុងកិច្ចព្រមព្រៀងពីរផ្នែក ។ ដំបូង កិច្ចព្រមព្រៀងទី១ធ្វើការពន្យារយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ រហូតដល់ទៅប្រាំឆ្នាំ ក្រោយពីសន្និបាតពិនិត្យឡើងវិញនេះ និងនៅពេលដែលប្រទេសជាភាគីទាំង៣០បានផ្តល់សច្ចាប័នលើវិសោធន

កម្ម ។ កិច្ចព្រមព្រៀងនេះធ្វើការលុបចោលរាល់កង្វល់ដូចកាលពីល្ងាចថ្ងៃសុក្រ ដែលតុលាការនឹងត្រូវបើកការពិភាក្សាលើឧក្រិដ្ឋកម្មឈ្លានពាន ប្រសិនបើក្រុមប្រឹក្សាសន្តិសុខបញ្ជូនរឿងក្តីឈ្លានពាននេះមកឲ្យតុលាការដោះស្រាយ ។ វាធ្លាប់មានជាទ្រឹស្តី និងកង្វល់ដូច្នេះកាលពីមុនមកដែរ ប៉ុន្តែការពិនិត្យកែលម្អនេះនឹងលុបចោលបញ្ហាទាំងអស់នោះ ។

កិច្ចព្រមព្រៀងទី៣ ធានាថាគោលការណ៍មិនប្រតិសកម្មនៃយុត្តាធិការលើរឿងព្រហ្មទណ្ឌនឹងមិនត្រូវបានលុបចោលនោះទេ ។ កិច្ចព្រមព្រៀងនេះចែងថា ៖ «យោងតាមកថាខ័ណ្ឌ១នៃមាត្រា១១នៃលក្ខន្តិកៈក្រុងរ៉ូម វាអាចយល់បានថាតុលាការមានយុត្តាធិការលើតែបទឧក្រិដ្ឋកម្មឈ្លានពានដែលប្រព្រឹត្តក្នុងរយៈពេលប្រាំឆ្នាំតែប៉ុណ្ណោះ ក្រោយពីការអនុម័តលើវិសោធនកម្មស្តីពីឧក្រិដ្ឋកម្មឈ្លានពាន និងរយៈពេលមួយឆ្នាំក្រោយការផ្តល់សច្ចាប័នទទួលស្គាល់វិសោធនកម្មដោយប្រទេសជាភាគីទាំង៣០» ។ ដូច្នេះយើងនឹងមិនចាំបាច់ព្រួយបារម្ភថានឹងមានការវិលត្រឡប់ទៅរកសភាពការដូចកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២នោះទេ នៅពេលដែលតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានអនុវត្តឲ្យក្លាយជាចំណុចចាប់ផ្តើមអនុវត្តយុត្តាធិការលើអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មឈ្លានពាន ។ សេចក្តីប្រកាសលើមាត្រា១២(៣) ដោយប្រទេសមិនមែនជាភាគី មិនអាចជម្រុញឲ្យតុលាការអនុវត្តយុត្តាធិការរបស់ខ្លួនលើការប្រព្រឹត្តឧក្រិដ្ឋកម្មឈ្លានពានមុននឹងការចាប់ផ្តើមឡើងនៃអាជ្ញាយុកាលនោះ ដោយសន្មត់ថាកិច្ចព្រមព្រៀងទី៣គឺត្រូវតែគោរពដោយចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងការអនុវត្តបកស្រាយ ។

ព័ត៌មានទាំងអស់នេះមិនត្រូវលាក់បាំងការពិតដែលថា ឯកសារក្រៅផ្លូវការរបស់លោកអគ្គរដ្ឋទូតវេណាវេសឺ គឺជាឯកសារដ៏សំខាន់ដែលមានជម្រុញឲ្យមានដំណើរការប្រតិបត្តិដ៏មានសក្តានុពលភាពលើឧក្រិដ្ឋកម្មឈ្លានពានយោងតាមលក្ខន្តិកៈក្រុងរ៉ូម ។ ជាមួយគ្នានេះ ក៏មានការព្រមព្រៀងលើការប្រើប្រាស់ពាក្យដែលដាក់ទស្សនៈខុសប្លែកគ្នាជាយូរមកហើយរួមបញ្ចូលគ្នា ។

ការកាត់ទោសជាអន្តរជាតិចុងក្រោយបង្អស់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬហៅថាឧក្រិដ្ឋកម្មឈ្លានពាននោះបានកើតឡើងនៅទីក្រុងនរីមប៊ឺច និងទីក្រុងតូក្យូ កាលពី៦៥ឆ្នាំកន្លងទៅ ។ នៅថ្ងៃសុក្រទី១១ ខែមិថុនា ឆ្នាំ២០១០ យើងអាចមើលឃើញនូវកិច្ចព្រមព្រៀងលើវិសោធនកម្មដែលបង្កើតជាតុលាការព្រហ្មទណ្ឌអន្តរជាតិនៅលើមាគ៌ាមួយ ឆ្ពោះទៅរកការកាត់ទោសស្រដៀងគ្នាលើបទឧក្រិដ្ឋកម្មឈ្លានពាននាពេលខាងមុខនេះ ។ សម្រាប់រូបខ្ញុំវិញ វាគឺជាការធ្វើដំណើរដែលមានរយៈពេល១៧ឆ្នាំចាប់ផ្តើមតាំងពីឆ្នាំ១៩៩៣មក ។ ខ្ញុំធ្លាប់ជាអ្នកប្រឹក្សាដ៏ចំណាស់ដល់អ្នកតំណាងអចិន្ត្រៃយ៍នៃអង្គការ

សហប្រជាជាតិប្រចាំសហរដ្ឋអាមេរិកគឺលោកស្រីបណ្ឌិត ម៉ាដែលីន អាល់ប្រាយ ហើយនេះក៏ជាកិច្ចការរបស់ខ្ញុំក្នុងការណែនាំ និងពន្យល់បកស្រាយពីបទឧក្រិដ្ឋកម្មឈ្លានពានដល់ភ្នាក់ងារសហព័ន្ធជាប់ពាក់ព័ន្ធ នៅក្នុងរដ្ឋាបាលរបស់លោក គ្លីនតុន ក្នុងនាមជាគណៈកម្មាធិការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិដែលចាប់ផ្តើមដាក់បញ្ចូលឧក្រិដ្ឋកម្មនេះទៅក្នុងសេចក្តីព្រាងនៃលក្ខន្តិកៈក្រុងរ៉ូម សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការច្បាប់អន្តរជាតិនៅឆ្នាំ១៩៩៤) ។

ខ្ញុំមិនទាន់ដឹងថា នឹងមានអ្វីកើតឡើងនៅថ្ងៃសុក្រនេះ នៅទីក្រុងកាំប៉ាឡានោះទេ ប៉ុន្តែខ្ញុំនឹងតាមដានដំណើរការនេះដោយការយកចិត្តទុកដាក់បំផុត និងដោយការត្រិះរិះពិចារណាឲ្យគ្រប់ជ្រុងជ្រោយរាល់អ្វីដែលបានកើតឡើងកាលពីរយៈពេលប៉ុន្មានឆ្នាំមុននេះ ។